## ១ សេចក្តីផ្តើម : ទស្សនៈអភិវឌ្ឍន៍វិស័យអប់រំ

### ១.១ ការឆ្លើយតបទៅនឹងគោលនយោបាយ និងអាទិភាពយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

ការកសាងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-១០ ឆ្លុះបញ្ចាំងអោយឃើញពីស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការកំណត់គោលដៅដ៏ច្បាស់លាស់របស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរួមចំណែកកសាងប្រទេសជាតិមាតុភូមិអោយមានការរីកចម្រើនខ្ពស់តាមរយៈ ***ការកសាងសមត្ថភាព និង អភិវឌ្ឍន៍ធនធានមនុស្ស*** ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-១០ បានដកស្រង់បទពិសោធន៍នានាដែលទទួលបានពីការអនុវត្តផែនការយុទ្ធ-សាស្ត្រវិស័យអប់រំឆ្នាំ ២០០១-០៥ ក៏ដូចជាលទ្ធផលនៃការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៤-០៨ កន្លងមកថ្មីៗនេះ ដែលសុទ្ធសឹងជាមូលដ្ឋានបង្អែកដ៏រឹងមាំ និងមានសារៈសំខាន់បំផុតដើម្បីធ្វើអោយផែនការយុទ្ធសាស្ត្រវិស័យអប់រំ មានលក្ខណៈជាក់ស្តែង និង អាចអនុវត្តបានប្រកបដោយជោគជ័យ ។

***ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស*** គឺជាយុទ្ធសាស្ត្រចម្បងមួយក្នុងចំណោមយុទ្ធសាស្ត្រសំខាន់ៗទាំងឡាយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី ៣ នៃរដ្ឋសភា ។ ក្រសួងអប់រំ យុវជន និង កីឡា បន្តយកចិត្តទុកដាក់ខ្ពស់លើ***ការពង្រឹងគុណភាពអប់រំ*** គ្រប់ភូមិសិក្សារួមមាន ការអប់រំកម្រិតមូលដ្ឋាន ក្រោយកម្រិតអប់រំមូលដ្ឋាន និងឧត្តមសិក្សា ។ គោលនយោបាយ និងយុទ្ធសាស្ត្រនានាដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-១០ ពិតជាជួយជម្រុញសកម្មភាពក្នុងការពន្លឿនល្បឿនកំណែទម្រង់វិស័យអប់រំក្នុងពេលបច្ចុប្បន្ន ឆ្ពោះទៅរកការសម្រេចអោយបាននូវរាល់ចំណុចដៅដែលបានកំណត់ទុកក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-១០ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ក៏ដូចជាឈានទៅសម្រេចអោយបានតាមគោលដៅនៃផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ ២០០៣-២០១៥ ។

ចំណុចសំខាន់ផ្សេងទៀតនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-១០ នេះគឺ ការបន្តពង្រឹងភាពជាដៃគូរវាងផ្នែកសាធារណៈ និងផ្នែកឯកជន ក្នុងការកៀរគរ និងប្រើប្រាស់ធនធានអោយមានប្រសិទ្ធភាពថែមទៀតដើម្បីសម្រេចជោគជ័យក្នុងកំណែទម្រង់វិស័យអប់រំ ។

### ១.២ គោលនយោបាយសំខាន់ៗរបស់វិស័យអប់រំ

**ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និង កីឡា :** ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺកសាង និង អភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាអោយក្លាយជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង និង ចំណេះធ្វើជាមូលដ្ឋាន ។

**បេសកកម្មរបស់ក្រសួងអប់រំ យុវជន និង កីឡា** : ដើម្បីសម្រេចបានតាមចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និង កីឡាមានបេសកកម្មដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និង កីឡានៃព្រះរាជាណាចក្រកម្ពុជា អោយឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់ និង សកលលោក ។

បេសកកម្មរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា សំដៅធានាថាយុវជន និងកុមារកម្ពុជាគ្រប់រូបមាន ឱកាសស្មើភាពគ្នាដើម្បីទទួលការអប់រំប្រកបដោយគុណភាព ស្របតាមរដ្ឋធម្មនុញ្ញ និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គម ទីតាំង ភូមិសាស្ត្រ ពូជសាសន៍ សាសនា ភាសា យេនឌ័រ និងកាយសម្បទា ។ ក្រសួងសង្ឃឹមទុកថា នៅពេលដែលសិស្ស និស្សិត បានបញ្ចប់ការសិក្សារបស់ខ្លួន ពួកគេនឹងមានចំណេះដឹងស្របតាមស្តង់ដាតំបន់ និងអន្តរជាតិ ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើពិភពលោក និងក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍសង្គម និង សេដ្ឋកិច្ច របស់ប្រទេសជាតិ ។

គោលបំណងចម្បងរបស់ក្រសួងអប់រំ យុវជន និង កីឡា គឺការអភិវឌ្ឍយុវជនកម្ពុជាសម្រាប់គ្រប់វិស័យ ។ លើសពីនេះទៀត ក្រសួងអប់រំ យុវជន និង កីឡា នឹងបណ្ដុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូប ឱ្យមានមោទនភាពជាតិ មានសីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និង ប្រជាពលរដ្ឋរបស់ខ្លួន ។

ក្រសួងអប់រំ យុវជន និង កីឡា បានកំណត់គោលនយោបាយធំៗ ៣ ដូចខាងក្រោម :

- ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប
- លើកកំពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ
- អភិវឌ្ឍស្ថាប័ន និងកសាងសមត្ថភាពសម្រាប់ធ្វើវិមជ្ឈការការងារអប់រំ ។

## ១.៣ ដំណើរការពិគ្រោះយោបល់ និងកសាងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-១០

បទពិសោធន៍ដែលទទួលបាន ពីការអនុវត្តកំណែទម្រង់ក្នុងវិស័យអប់រំតាមរយៈ ***អភិក្រមគ្រប់គ្រងទូទាំងវិស័យ*** បានផ្តល់នូវលទ្ធផលជាផ្លែផ្កាល្អ ក្នុងដំណើរការពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ/អង្គការក្រៅរដ្ឋាភិបាល និង អ្នកពាក់ព័ន្ធផ្សេងៗទៀត ជាពិសេសក្នុងការរៀបចំចងក្រងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ។ ការផ្ទេរពីភាពជាអ្នកផ្តល់ជំនួយ ទៅរកភាពជាដៃគូ និងឈានទៅរកភាពជាម្ចាស់របស់រាជរដ្ឋាភិបាលកម្ពុជា បានស្តែងចេញអោយឃើញនូវកិច្ចសហប្រតិបត្តិការដ៏ល្អពីគ្រប់ភាគីដែលពាក់ព័ន្ធទាំងឡាយ ។ ក្រសួងអប់រំ យុវជន និង កីឡា បានអនុវត្តដោយជោគជ័យក្នុងការកសាងភាពជាដៃគូ ក្នុងបរិបទសុខដុមនីយកម្មនៃការផ្តល់ និងទទួលជំនួយ ពីខាងក្រៅ ។

ជាក់ស្តែង ក្រសួងអប់រំ យុវជន និង កីឡា មានយន្តការពិគ្រោះយោបល់ច្បាស់លាស់ជាមួយអ្នកផ្តល់ជំនួយ តាមរយៈក្រុមការងារបច្ចេកទេសចម្រុះក្នុងវិស័យអប់រំ ដែលមានសមាសភាពជាថ្នាក់ដឹកនាំ មន្ត្រីអប់រំ និង មន្ត្រីមកពីក្រសួងពាក់ព័ន្ធ ព្រមទាំងតំណាងអ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាលនៃក្រុមការងារអ្នកផ្តល់ជំនួយក្នុងវិស័យអប់រំ ។

ដើម្បីរៀបចំកសាងគោលនយោបាយ និង យុទ្ធសាស្ត្រវិស័យអប់រំសម្រាប់ពេលអនាគត ក្រសួងអប់រំ យុវជន និង កីឡា បានអនុវត្តគំនិតផ្តួចផ្តើមក្នុងការពិគ្រោះយោបល់ដ៏ទូលំទូលាយ ដែលរួមមាន :

- ការពិគ្រោះយោបល់ជាមួយក្រសួងអប់រំ យុវជន និង កីឡា ខ្លួនឯងផ្ទាល់ និងមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង បានធានាថា ផែនការយុទ្ធសាស្ត្រវិស័យអប់រំដែលបានរៀបចំកសាងឡើងនេះ គឺសំដៅឈានទៅសម្រេចគោលដៅទាំងឡាយដែលបានលើកឡើងក្នុងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ ២០០៣ -២០១៥ ។
- ការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នដែលពាក់ព័ន្ធទាំងអស់ ជាពិសេសជាមួយក្រសួងផែនការ ដើម្បីធានាថា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ពិតជាឆ្លើយតបតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា និង បានរួមចំណែកដល់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-១០ ព្រមទាំងស៊ីសង្វាក់គ្នាជាមួយយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ក៏ដូចជាគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាផងដែរ ។
- ការពិគ្រោះយោបល់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគោលបំណងធានាថា ធនធានថវិកាដែលបានលើកឡើងក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-១០ មានលក្ខណៈជាក់ស្តែង សមស្រប និង អាចទទួលបានការគាំទ្រពិតប្រាកដ ។
- ការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាជាតិកំណែទម្រង់រដ្ឋបាល ដើម្បីធានាថាដំណើរការកែទម្រង់វិស័យអប់រំទាំងមូល ពិតជាឆ្លើយទៅនឹងទិសដៅនៃកំណែទម្រង់រដ្ឋបាលសាធារណៈពិតប្រាកដមែន ទាំងការរៀបចំការប្រើប្រាស់បុគ្គលិក ក៏ដូចជាការរៀបចំកាំប្រាក់បៀវត្សរ៍បានល្អ ជូនដល់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ។
- ការពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធមួយចំនួនទៀតគឺ ដើម្បីធានាថារាល់បញ្ហាដែលពាក់ព័ន្ធគ្នាជាអន្តរវិស័យ ត្រូវបានលើកយកមកដោះស្រាយយ៉ាងយកចិត្តទុកដាក់បំផុត ជាពិសេសបញ្ហារីករាលដាលនៃ HIV/AIDS ភាពពិការ និង បញ្ហាយេនឌ័រជាដើម ។
- ការពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេសចំរុះសម្រាប់វិស័យអប់រំ ដើម្បីបង្ហាញពីការចូលរួមយ៉ាងសកម្មរបស់ភាគីផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងវិស័យអប់រំ ។

ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-១០ ក្រសួងបានរៀបចំវេទិកាពិគ្រោះយោបល់ថ្នាក់តំបន់ចំនួន ៤ ដើម្បីផ្តល់ព័ត៌មានពីគោលនយោបាយអាទិភាពសំខាន់ៗ ដល់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ព្រមទាំង ទទួលបានមតិយោបល់កែលំអផងដែរ ។

ឯកសារផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-១០ នឹងត្រូវបានអនុម័តជាឯកសារផ្លូវការរបស់ក្រសួង និង ផ្សព្វផ្សាយទូទាំងប្រទេសសម្រាប់ប្រើប្រាស់ទូទៅ ។ ឯកសារនេះក៏ត្រូវបានផលិតជាស៊ីឌី (Compact Disk) ជាភាសាខ្មែរ និង ភាសាអង់គ្លេស ព្រមទាំងបង្ហាញជូនតាមរយៈគេហទំព័ររបស់ក្រសួងអប់រំ យុវជន និង កីឡាទៀតផង ។ សូមអញ្ជើញបើកគេហទំព័រ : www.moeys.gov.kh ។